IHSS IN-HOME SUPPORTIVE SERVICES

CDSS

# ការមើលស្គាល់នូវអាកប្បកិរិយារំលោភបំពាន

ពេលខ្លះអ្នកផ្តល់សេវា សមាជិកគ្រួសារ (រួមទាំងកូនក្មេង) ឬ មិត្តភ័ក្តិដើរខុសគន្លងនៃច្បាប់ ហើយក្លាយជាការរំលោភបំពាន។

នៅរដ្ឋកាលីហ្វ័រនីញ៉ា ការរំលោភបំពានលើកូនក្មេង លើបុគ្គលដែលមានអាយុលើសពី 65 ឆ្នាំ ឬនរណាម្នាក់ដែលមានអាយុចន្លោះពី 18 ទៅ 64 ឆ្នាំ ដែលមានស្ថានភាពសុខភាពរាងកាយ ឬផ្លូវចិត្តមានភាពទន់ខ្សោយ គឺជាបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមច្បាប់។

ការរំលោភបំពានអាចកើតឡើងតាមវិធីច្រើនយ៉ាង រួមទាំង ការរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ការរំលោភបំពានផ្នែកហិរញ្ញវត្ថុ ការទុកចោលដោយមិនយកចិត្តទុកដាក់ និងការរំលោភបំពានផ្លូវចិត្ត ឬការគំរាមកំហែង។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃការរំលោភបំពាន៖

- ត្រូវបានគេទះ វាយ ច្របាច់ក ក្តិច ទាត់ រុញ ចាប់រំលោភ ឬរំលោភធ្វើបាប។
- ត្រូវបានគេស្រែកជេរឥតឈប់ឈរ គំរាមកំហែងដល់រាងកាយ ឬគំរាមកំហែងថានឹងទុកឱ្យនៅម្នាក់ឯង។
- ត្រូវបានទុកឱ្យនៅម្នាក់ឯង ដោយអ្នកផ្តល់សេវាថែទាំ នៅពេលដែលអ្នកមិនអាចទទួលបានអាហារ ទឹក សំលៀកបំពាក់ ទីជម្រក ឬការថែទាំសុខភាពដែលចាំបាច់។
- ត្រូវបានគេបង្ខាំងពីការទទួលបានសំបុត្រ ការហៅទូរស័ព្ទ ឬភ្ញៀវ។ ឬ រារាំងមិនឱ្យអ្នកចាកចេញពីផ្ទះ ដោយគ្មានហេតុផលត្រឹមត្រូវ។
- មានលុយ ទ្រព្យសម្បត្តិ ឬវត្ថុមានតម្លៃត្រូវបានគេយកដោយបង្ខំ ឬដោយគ្មានការអនុញ្ញាតពីអ្នក។
- ត្រូវបានមិនយកចិត្តទុកដាក់ដោយនរណាម្នាក់ ដែលគួរតែផ្តល់ការថែទាំ ម្ហូបអាហារ ឬទឹក។

## រាយការណ៍អំពីការរំលោភបំពាន!

ប្រសិនបើអ្នកត្រូវបានគេរំលោភបំពាន សូម្បីតែដោយសមាជិកគ្រួសារក៏ដោយ អ្នកគួរតែទៅរកគេជួយភ្លាមៗដោយទាក់ទងទៅ៖

- 911
- សេវាការពារមនុស្សពេញវ័យ (APS) តាមលេខទូរស័ព្ទពិសេសផ្នែក APS របស់រដ្ឋកាលីហ្វ័រនីញ៉ា: (833) 401-0832

**សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងការិយាល័យខោនធីផ្នែក IHSS ក្នុងតំបន់របស់អ្នក។**